
សំរាប់កុមារជុំវិញពិភពលោក!
តោះយើងនាំគ្នាលាងដៃទាំងអស់គ្នា
លាងដៃដើម្បីការពារសុខភាពរបស់យើង
Handwashing for health and life
1
ខ្ញុំបានដឹងថាយើងត្រូវលាងដៃជាមួយសាប៊ូតាំងពីខ្ញុំនៅតូច
2
តើយើងគួរលាងដៃនៅពេលណា?
3
នៅពេលអ្នកត្រលប់មកពីខាងក្រៅវិញ
ចូរប្រញាប់លាងដៃពេលយើងមកដល់ផ្ទះ
ចាស
4
ក្រោយពេលចេញពីបង្គន់
5
មុនពេលហូបបាយនិងអាហារផ្សេងៗ
តើអ្នកបានលាងដៃហើយឬនៅ?
រួចហើយ
ហូបបាយសិន
6
ហេតុអ្វីបានជាអ្នកលាងដៃបែបនេះ?
7
ដៃនិងម្រាមដៃហាក់មានអនាម័យល្អ
ប៉ុន្តែមានបាក់តេរីច្រើនដែលយើងមើលមិនឃើញ
8
ហូបបាយដោយមិនបានលាងដៃ
នៅពេលអ្នកប៉ះមុខអ្នក បាក់តេរីនឹងចូលតាមភ្នែក មាត់ និងច្រមុះអ្នក
9
អ្នកនឹងឈឺពោះ
10
អ្នកនឹងមានជំងឺ
11
ខ្ញុំក៏បានដឹងថាយើងត្រូវលាងដៃជាមួយសាប៊ូក្រោយពេលយើងប៉ះសត្វ
ក្រោយពេលយើងប៉ះសំរាមក៏ដោយ


12
មើល! ខ្ញុំលាងដៃបែបនេះ!
13
វាមិនបាត់មេរោគទេ បើយើងគ្រាន់តែផ្សើមដៃជាមួយទឹក
ស្អី?! មែន?!
14
មេរោគខ្លាចពពុះសាប៊ូ
ដូច្នេះ យើងត្រូវកំចាត់មេរោគដោយពពុះសាប៊ូ
SOAP
អូ!
15
វិធីលាងសំអាតដៃ ដោយប្រើសាប៊ូ
1 2 3 4…
១-២-៣-៤ សូមលាងដៃយឺតៗ ដោយរាប់ដល់ ៣០
សូមលាងសំអាតដៃជាមួយពពុះសាប៊ូ
ផ្សើមដៃជាមួយទឹក
ធ្វើឱ្យមានពពុះសាប៊ូ
លាងបាតដៃ
លាងខ្នងដៃ
លាងមេដៃទាំងពីរ
លាងចន្លោះម្រាមដៃ
លាងចន្លោះក្រចក
លាងកដៃទាំងពីរ
16
ចុងក្រោយយើងត្រូវលាងសាប៊ូចេញឱ្យស្អាតជាមួយទឹក
ជូតដៃដោយកន្សែងស្អាតឬស្ងួតឱ្យបានល្អ! វាជាការស្រេចហើយ!
17
ប៉ុន្តែ នៅភូមិខ្ញុំគ្មានទឹកស្អាតទេ។ ខ្ញុំត្រូវដើរទៅយកទឹករាប់គីឡូ។
នៅភូមិខ្ញុំមានទឹកស្អាតប៉ុន្តែពេលខ្លះទឹកមិនចេញទេ។
ដូច្នេះខ្ញុំមិនអាចប្រើទឹកច្រើនសំរាប់លាងដៃទេ
18
ហ្អឹងហើយទឹកមានសារះសំខាន់ណាស់? មិនអញ្ចឹង?
មានវិធីលាងដៃឱ្យបានត្រឹមត្រូវដោយប្រើទឹកតិច
Tippy - Tap
នៅពេលអ្នកជាន់ដំបងខាងក្រោម ទឹកចេញមកបន្តិចម្តងៗ
សាប៊ូ
ឧបករណ៍លាងដៃ
ទឹកចេញពេលយើងមួលវា
ប្រើកំសៀវដើម្បីលាងដៃ
អាចលាងដៃជាមួយកែវទឹក
ដាក់ទឹកចូលក្នុងកំសៀវហើយចាក់ទឹកលាងដៃ
សាប៊ូ
ប្រើទឹកស្អាតតាមដែលអាចធ្វើទៅបាន
19
តោះគិតជាមួយគ្នានិងកម្ចាត់មេរោគនៅលើដៃកុមារជុំវិញពិភពលោក
ដើម្បីបង្កើនចំនួនកុមារដែលមានសុខភាពល្អ

គំនូរ: អ៊ីណូអេ គិមីដូរី